ភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩

អង្គការសង្គមស៊ីវិលកម្ពុជា ជម្រុញឲ្យរាជរដ្ឋាភិបាលកម្ពុជាចាត់វិធានការបន្ទាន់ ដើម្បីអនុវត្តនូវអនុសាសន៍ថ្មី របស់គណៈកម្មាធិការរបស់អង្គការសហប្រជាជាតិ ដែលទទួលបន្ទុកត្រួតពិនិត្យការអនុវត្តរបស់ប្រទេសកម្ពុជាលើអនុសញ្ញាស្តីពីសិទ្ធិស្រ្តី។

គណៈកម្មាធិការរបស់អង្គការសហប្រជាជាតិ ទទួលបន្ទុកអនុសញ្ញាស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្រ្តី (Convention on the Elimination of all Forms of Discrimination Against Women - CEDAW) បានពិចារណាទៅលើរបាយការណ៍វឌ្ឍនភាពចុងក្រោយរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងសម័យប្រជុំត្រួតពិនិត្យឡើងវិញលើកទី៧៤ នៅក្នុងឆ្នាំ ២០១៩ នេះ។ គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្រ្តី (ហៅកាត់ថា NGO-CEDAW) បានធ្វើការស្វែងរកមតិគាំទ្រសម្រាប់អនុសាសន៍ជាក់លាក់ នៅក្នុងដំណើរការនេះ តាមរយៈការដាក់នូវរបាយការណ៍មុនវគ្គ នៅខែមីនា ឆ្នាំ២០១៩ និងរបាយការណ៍ស្រមោល នៅខែតុលា ឆ្នាំ២០១៩ សម្រាប់សម័យប្រជុំត្រួតពិនិត្យឡើងវិញ របស់គណៈកម្មាធិការទទួលបន្ទុកអនុសញ្ញា ស៊ីដ។ NGO-CEDAW ក៏បានបញ្ជូនតំណាងសង្គមស៊ីវិលទៅជួបផ្ទាល់ជាមួយគណៈកម្មាធិការទទួលបន្ទុកអនុសញ្ញា ស៊ីដ នៅទីក្រុង ហ្សឺណែវ នៃប្រទេសស្វីស។ គណៈកម្មាធិការទទួលបន្ទុកអនុសញ្ញា ស៊ីដ បានដាក់ចេញនូវអនុសាសន៍ជាលាយលក្ខណ៍អក្សរ នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ដល់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់សកម្មភាពបួនឆ្នាំបន្ទាប់។ អនុសាសន៍ទាំងនោះ រាជរដ្ឋាភិបាលត្រូវតែយកទៅអនុវត្ត ដើម្បីឈានទៅដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព ទី៥ នៃការសម្រេចបាននូវសមភាពយេនឌ័រ នៅឆ្នាំ២០៣០។

ជាពិសេស អង្គការសង្គមស៊ីវិល ដែលបានចូលរួមក្នុងសិក្ខាសាលាផ្សព្វផ្សាយរបស់អង្គការសង្គមស៊ីវិលលើ សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការទទួលបន្ទុកអនុសញ្ញា ស៊ីដ ចំពោះប្រទេសកម្ពុជា បានលើកយកអនុសាសន៍សំខាន់ៗ របស់គណៈកម្មាធិការទទួលបន្ទុកអនុសញ្ញា ស៊ីដ ដូចខាងក្រោម៖

១. ពង្រឹងក្របខ័ណ្ឌច្បាប់ (កថា ៨ និង ៩ នៃសេចក្តីសង្កេតសន្និដ្ឋាន)
២. ថវិកា និងយន្តការជាតិ សម្រាប់ការរីកចម្រើនរបស់ស្ត្រី (កថា ១៤ និង ១៥)
៣. សេរីភាពបញ្ចេញមតិសម្រាប់សង្គមស៊ីវិល (បុគ្គល អង្គការ និងសមាគម) (កថា ១៨ និង ១៩)
៤. ការអប់រំ (កថា ៣៤ និង ៣៥)

បញ្ជីពេញលេញនៃសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការទទួលបន្ទុកអនុសញ្ញា ស៊ីដ ជាភាសាអង់គ្លេស អាចទាញពីតំណរនេះ https://tbinternet.ohchr.org/_layouts/15/treatybodyexternal/Download.aspx?symbolno=CEDAW%2fC%2fKHM%2fCO%2f6&Lang=en

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមក ៖

- កញ្ញា បុណ្យ រចនា, នាយិកាអង្គការក្លាហាន 089 476 146
- កញ្ញា ឌួង ច័ន្ទសិរីវិសាល នាយិកាអង្គការបន្ទាយស្រី 012 489 358
- កញ្ញា Nassima El Ouady អង្គការ Planète Enfants & Développement 099 278 467
- អ្នកស្រី សូ សុម៉ាល័យ អង្គការ Solidarity Center 085 679 467
- អ្នកស្រី អេង ចាន់ឌី អង្គការ GADC 095 797 909
- អ្នកស្រី សាផន សុមោលីរស្មី អង្គការ RHAC 085 250 368
- អ្នកស្រី ជឹម ចាន់នាង NGO-CEDAW 012 668 853